Institut Pasteur du Cambodge

*រៀបរៀងដោយ វេជ្ជ.ហេង ណៃឃីម / វេជ្ជ.ពឹង យ៉ីកស៊ីង / ខែមេសា ឆ្នាំ២០១៥*

# វ៉ាក់សាំងបង្ការជំងឺរលាកស្រោមខួរ ( Meningococcique A+C Vaccine )

## ១- ដូចម្តេចដែលហៅថាជំងឺរលាកស្រោមខួរក្បាល?

វាគឺជាជំងឺដ៏ធ្ងន់ធ្ងរមួយដែលបង្កដោយបាក់តេរីមេណាំងហ្គូកូក។ បាក់តេរីនេះជាមូលហេតុនាំមុខគេដែលបង្កជាជំងឺរលាកស្រោមខួរក្បាលលើកុមារអាយុពី ២-១៨ឆ្នាំ ហើយមេរោគនេះក៏អាចបណ្តាលអោយមានការសាយភាយមេរោគ ទៅតាមប្រព័ន្ធឈាមរត់ទាំងមូលផងដែរ (septicémie) ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជីវិតក្នុងករណីខ្លះ បើទោះបីជាមានការព្យាបាលយ៉ាងត្រឹមត្រូវក៏ដោយ។



មនុស្សគ្រប់វ័យអាចប្រឈមមុខនឹងជំងឺបង្កដោយមេរោគមេណាំងហ្គូកូក។ ប៉ុន្តែគេឃើញកើតញឹកញាប់ជាងគេទៅលើកុមារអាយុក្រោម ១ឆ្នាំ និងអ្នកមានអាយុពី ១៦-២១ ឆ្នាំ។ បញ្ហាផ្សេងទៀតដូចជា ការកាត់យកអណ្តើកចេញ និងការចុះខ្សោយនៃប្រព័ន្ធភាពស៊ាំក៏បង្កើនឱកាសនៃការឆ្លងរោគនេះផងដែរ។
ជំងឺនេះអាចបង្ការដោយវ៉ាក់សាំងប្រឆាំងនឹងមេរោគមេណាំងហ្គូកូក ប្រភេទអា និងប្រភេទសេ (Neisseria meningitidis group A+C) លើមនុស្សពេញវ័យ និងកុមារអាយុចាប់ពី ២ ឆ្នាំឡើងទៅ។

## ២- តើអ្នកណាខ្លះគួរទទួលវ៉ាក់សាំងបង្ការនេះ?

- អ្នកដែលធ្វើរដំណើរឆ្លងកាត់ រឺរស់នៅក្នុងតំបន់ណាដែលមានវត្តមាននៃការឆ្លងជំងឺនេះ
- អ្នកដែលមានសរីរាង្គអណ្តើកបំពេញមុខងារមិនបានល្អ (ខ្សោយ) រឺអ្នកដែលត្រូវបានវះកាត់យកអណ្តើកចេញ
- អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ
- អ្នកដែលគិតថាបានប្រឈមមុខ ក្នុងការឆ្លងមេរោគនេះ ក្នុងអំឡុងពេលនៃការឆ្លងរាតត្បាតនៃមេរោគប្រភេទនេះ
- អ្នកមន្ទីរពិសោធន៍ដែលអាចប្រឈមមុខនឹងការឆ្លងមេរោគនេះ

## ៣- តើគេផ្តល់វ៉ាក់សាំងនេះយ៉ាងដូចម្តេច?

ចាក់តែមួយដូសគត់ សំរាប់មនុស្សពេញវ័យ និង សំរាប់កុមារដែលមានអាយុចាប់ពី ២ឆ្នាំឡើងទៅ។

## ៤- តើអ្នកណាខ្លះដែលមិនគួរទទួលវ៉ាក់សាំងប្រភេទនេះ?

- កុមារដែលមានអាយុតិចជាង ២ ឆ្នាំ
- អ្នកដែលធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន រឺធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀត ដែលមានក្នុងវ៉ាក់សាំងនេះ។

## ៥- តើវ៉ាក់សាំងនេះអាចបណ្តាលអោយមានផលវិបាកអ្វីខ្លះ?

ដូចឱសថផ្សេងទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាលែកស៊ីជាដើម។ ប៉ុន្តែករណីដែលអាចបង្កឲ្យមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ការឡើងក្រហម រឺឈឺត្រង់កន្លែងចាក់
- ក្តៅខ្លួនបន្តិចបន្តួច
- ប្រតិកម្មអាលែកស៊ីធ្ងន់ធ្ងរ (ប៉ុន្តែកម្រជួបប្រទះ) : អ្នកជំងឺអាចមានអាការៈដូចជាពិបាកដកដង្ហើម ហើមណៃនក្នុងបំពង់ក ទន់ដៃជើង ហ៊ឹងត្រចៀក វិលមុខ ចង្វាក់ដង្ហើមញាប់ បេះដូងដើរញាប់ រមាស់ពេញខ្លួន ស្លេកស្លាំង...

**ប្រសិនបើមានសញ្ញាប្រតកម្មធ្ងន់ធ្ងរ សូមជូនដំណឹងនេះដល់គ្រូពេទ្យរបស់អ្នកជាបន្ទាន់**